# គោលការណ៍ណែនាំរបស់ OECD សម្រាប់សហគ្រាសពហុជាតិ

## តើក្រុមហ៊ុន អាជីវកម្មពហុជាតិ បានបង្កគ្រោះថ្នាក់ដល់អ្នកសហគមន៍ ឬបរិស្ថានរបស់អ្នកឬទេ?



ពួកគេអាចបានបំពាន គោលការណ៍ណែនាំរបស់ OECD (អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច) សម្រាប់សហគ្រាស ពហុជាតិ ... ‘ចំណុចទំនាក់ទំនងថ្នាក់ជាតិ’ អាចជួយបាន!

‘ក្រុមហ៊ុនអាជីវកម្មពហុជាតិ’ គឺជា ក្រុមហ៊ុនអាជីវកម្មដែលធ្វើប្រតិបត្តិការនៅ ក្នុងប្រទេសលើសពីមួយ។ ក្រុមហ៊ុនអាជីវកម្មក្នុងស្រុកអាចជាផ្នែកនៃក្រុមហ៊ុនអាជីវកម្មពហុជាតិ។

## តើអ្វីខ្លះជា ‘គោលការណ៍ណែនាំរបស់ OECD’?



**គោលការណ៍ណែនាំរបស់** OECD **សម្រាប់សហគ្រាសពហុជាតិស្តីពីការប្រតិបត្តិអាជីវកម្មប្រកបដោយការទទួលខុសត្រូវ** (គោលការណ៍ណែនាំរបស់ OECD) គឺជាស្តង់ដារនៃអាកប្ប កិរិយា

ដែលលើកទឹកចិត្តឲ្យក្រុមហ៊ុនអាជីវកម្មពហុជាតិអនុវត្តប្រកបដោយការទទួលខុសត្រូវ នៅគ្រប់កន្លែងទាំងអស់ដែលខ្លួនធ្វើប្រតិបត្តិការ។ គោលការណ៍ណែនាំរបស់ OECD មាន គ្របដណ្តប់លើសិទ្ធិមនុស្ស សិទ្ធិការងារ បរិស្ថាន និងបញ្ហាផ្សេងៗទៀត។

> OECD នេះ គឺជាអង្គការអន្តររដ្ឋាភិបាលមួយដែលផ្សព្វផ្សាយពីស្តង់ដារអន្តរជាតិនានា។

## តើអ្វីជា ‘ចំណុចទំនាក់ទំនងថ្នាក់ជាតិ’?

ជាង 50 ប្រទេសមាន**ចំណុចទំនាក់ទំនងថ្នាក់ជាតិសម្រាប់ការប្រតិបត្តិអាជីវកម្មប្រកប ដោយការទទួលខុសត្រូវ**ដើម្បីជួយដោះស្រាយបណ្តឹងតវ៉ាប្រឆាំងនឹងក្រុមហ៊ុនអាជីវកម្មពហុជាតិ’ ដែល បាន ភ្ជាប់នឹងប្រទេសទាំងនោះ។ ប្រទេសទាំងនោះមានចុះក្នុងបញ្ជីនៅគេហទំព័រ OECD

## តើបញ្ហាអ្វីខ្លះដែលខ្ញុំអាចប្តឹងតវ៉ាបាន?



អ្នកអាចប្តឹងតវ៉ាអំពីការប្រតិបត្តិអាជីវកម្មទាក់ទងនឹង ៖

- សិទ្ធិមនុស្ស សិទ្ធិការងារ បរិស្ថាន និងការប្រែប្រួលធាតុអាកាស
- ការលាតត្រដាងពីសាជីវកម្ម អំពើពុករលួយ អាកប្បកិរិយាប្រឆាំងនឹងការប្រកួតប្រជែង ហើយនិងការគេចពន្ធ
- វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងការការពារអ្នកប្រើប្រាស់ប្រកបដោយការទទួលខុសត្រូវ។

សូមមើល គេហទំព័រគោលការណ៍ណែនាំរបស់ OECD សម្រាប់ព័ត៌មានបន្ថែម។

# ប្រទេសខ្ញុំពុំមានចំណុចទំនាក់ទំនងថ្នាក់ជាតិទេ។ តើខ្ញុំនៅតែអាចប្ដឹងតវ៉ាបានទេ?

ប្រាកដណាស់ បាន! អ្នកអាចប្ដឹងតវ៉ាទៅចំណុចទំនាក់ទំនងថ្នាក់ជាតិរបស់ប្រទេសមួយទៀតបាន ប្រសិនបើក្រុមហ៊ុនអាជីវកម្មពហុជាតិដែល អ្នកប្ដឹងតវ៉ានោះ បានភ្ជាប់ជាមួយនឹងប្រទេសនោះ។ បានភ្ជាប់មានន័យថា ក្រុមហ៊ុនអាជីវកម្មនោះ

- មកពី ប្រទេសមួយដែលមានចំណុចទំនាក់ទំនងថ្នាក់ជាតិ ឬ
- កំពុងធ្វើប្រតិបត្តិការនៅក្នុង ប្រទេសមួយដែលមានចំណុចទំនាក់ទំនងថ្នាក់ជាតិ។

ឧទាហរណ៍ ក្រុមហ៊ុននោះអាចបានភ្ជាប់ ប្រសិនបើទីស្នាក់ការធំរបស់ខ្លួនស្ថិតនៅក្នុងប្រទេសមួយដែលមានចំណុចទំនាក់ទំនងថ្នាក់ជាតិ ឬវាមានអាជីវកម្មឬទ្រព្យសម្បត្តិនៅក្នុងប្រទេសមួយដែលមានចំណុចទំនាក់ទំនងថ្នាក់ជាតិ។

# តើខ្ញុំប្ដឹងតវ៉ាដោយរបៀបណា?

ដំបូង ជ្រើសរើសចំណុចទំនាក់ទំនងថ្នាក់ជាតិនៅក្នុងប្រទេសមួយដែលបានភ្ជាប់នឹងក្រុមហ៊ុនអាជីវកម្មនោះ(សូមមើលខាងលើ) ហើយធ្វើការប្ដឹងតវ៉ាដោយមើលតាមជំហានមួយចំនួនក្នុងគេហទំព័ររបស់ពួកគេ។

បណ្ដឹងតវ៉ារបស់អ្នកត្រូវបញ្ជាក់ថាតើអ្នកគិតថាក្រុមហ៊ុនអាជីវកម្មនោះបានបំពានលើគោលការណ៍ណែនាំរបស់ OECD យ៉ាងដូចម្ដេច ហើយអ្វីខ្លះដែលអ្នកចង់ឲ្យក្រុមហ៊ុននោះធ្វើ។

អ្នកក៏អាចសុំឲ្យអ្នកដទៃណាម្នាក់ ដូចជាអង្គការក្រៅរដ្ឋាភិបាល (NGO) ធ្វើការប្ដឹងតវ៉ាក្នុងនាមអ្នកបានដែរ។

OECD Watch (ការឃ្លាំមើលរបស់ OECD) គឺជាបណ្ដាញនៃសហគមន៍និង NGO សកល មានឱវាទអំពីការសរសេរពាក្យបណ្ដឹងតវ៉ាប្រកបដោយប្រសិទ្ធិភាព

ឧទាហរណ៍ ៖ ស្កេនលេខកូដដើម្បីមើល ទម្រង់បែបបទបណ្ដឹងតវ៉ារបស់ចំណុចទំនាក់ទំនងថ្នាក់ជាតិនៅ ប្រទេសអូស្ដ្រាលី

## តើមានអ្វីកើតឡើងនៅពេលខ្ញុំប្ដឹងតវ៉ា?

ចំណុចទំនាក់ទំនងថ្នាក់ជាតិនោះនឹងពិនិត្យពាក្យបណ្តឹងរបស់អ្នកដែលពាក់ព័ន្ធនឹងក្រុមហ៊ុនអាជីវកម្មពហុជាតិដែលបានភ្ជាប់ជាមួយប្រទេសដែលមានចំណុចទំនាក់ទំនងថ្នាក់ជាតិ ហើយសកម្មភាពនានារបស់ក្រុមហ៊ុននោះមានទាក់ទងនឹងគោលការណ៍ណែនាំរបស់។

បើដូច្នោះមែន ចំណុចទំនាក់ទំនងថ្នាក់ជាតិនោះអាចជួយអ្នកក្នុងការចរចារជាមួយនឹងក្រុមហ៊ុនអាជីវកម្មនោះ ឬសុំឲ្យក្រុមហ៊ុននោះផ្តល់ព័ត៌មានដែលដោះស្រាយបណ្តឹងតវ៉ារបស់អ្នក។ ចំណុចទំនាក់ទំនងថ្នាក់ជាតិខ្លះអាចបោះពុម្ពផ្សាយសេចក្តីថ្លែងការណ៍មួយថា តើខ្លួនគិតឬមិនគិតថាក្រុមហ៊ុនអាជីវកម្មនោះបានអនុវត្តប្រកបដោយការទទួលខុសត្រូវតាមគោលការណែនាំរបស់ OECD ឬអត់។

បណ្តឹងតវ៉ាទាំងពួងគឺមានការរក្សាភាពសម្ងាត់ ប៉ុន្តែធម្មតាអ្នកត្រូវការអនុញ្ញាតឲ្យចំណុចទំនាក់ទំនងថ្នាក់ជាតិនោះចែករំលែកព័ត៌មានខ្លះជាមួយក្រុមហ៊ុនអាជីវកម្មនោះដើម្បីឱ្យពួកគេអាចឆ្លើយតបវិញដោយមានន័យ។ ប្រសិនបើអ្នកបារម្ភថាបណ្តឹងតវ៉ារបស់អ្នកអាចធ្វើឲ្យអ្នកស្ថិតក្នុងភាពគ្រោះថ្នាក់ អ្នកអាចសួរទៅចំណុចទំនាក់ទំនងថ្នាក់ជាតិ ថាតើគេអាចជួយក្នុងបញ្ហានេះដោយវិធីណា ឧទាហរណ៍ តាមរយៈបណ្តឹងតវ៉ាជាអនាមិក។

## ហេតុអ្វីបានជាត្រូវប្ដឹងទៅ ‘ចំណុចទំនាក់ទំនងថ្នាក់ជាតិ’?

ការប្តឹងទៅចំណុចទំនាក់ទំនងថ្នាក់ជាតិធ្វើឲ្យសាធារណជនដឹង និងមានន័យថា មានភាគរយកាន់តែខ្ពស់ដែលក្រុមហ៊ុនអាជីវកម្មនោះចាត់វិធានការលើពាក្យបណ្តឹងរបស់អ្នកដោយយកចិត្តទុកដាក់។ បន្ទាប់ពីកិច្ចសន្ទនាហើយ ក្រុមហ៊ុនអាជីវកម្មនោះអាចសម្រេចប្តូរអាកប្បកិរិយា របស់ខ្លួន ធ្វើការសុំទោស ឬជួយដោះស្រាយបញ្ហានានា។ ចំណុចទំនាក់ទំនងថ្នាក់ជាតិទាំងពួងមិនមែនជាតុលាការ ឬប៉ូលិសទេ ដូច្នេះគេឥតគិតថ្លៃ ហើយអ្នកមិនត្រូវការមេធាវីទេ។ ហើយ ប្រសិនបើអ្នកជ្រើសរើស អ្នកក៏អាចដកបណ្តឹងតវ៉ារបស់អ្នកពេលណាក៏បាន។ សូមស្វែងយល់បន្ថែមទៀតនៅថ្ងៃនេះ!